https://www.vodkhmer.news/2020/05/19/factory-worker-canadia-protested-blockade-after-owners-refused-transport-items-been- Go
12 captures
27 Sep 2020 - 22 Mar 2024
SEP MAR APR
22
2023 2024 2025
About this capture



# កម្មករនៅសួនកាណាឌីយ៉ាបិទផ្លូវ ក្រោយពីម្ចាស់សួនមិនឱ្យដឹកសម្ភារដែលលក់ឡាយឡុងចេញ



លោក យុត សុគន្ធ | ១៩ ឧសភា ២០២០ ម៉ោង ១៥:៤៧




កម្មករនៅរោងចក្រកាត់ដេរសម្លៀកបំពាក់ អ៊ិនធើណាស្យូណាល់ ហ្វេសស៊ិន រ៉ូយ៉ាល់ (INTERNATIONAL FASHION ROYAL CO., LTD) នៅសួនឧស្សាហកម្មកាណាឌីយ៉ា ស្ថិតក្នុងសង្កាត់ចោមចៅ តវ៉ាបិទផ្លូវដើម្បីសុំម្ចាស់សួនអនុញ្ញាតឱ្យអ្នកទិញសម្ភារលក់ឡាយឡុងពីរោងចក្រ ដឹកសម្ភារចេញពីរោងចក្រ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០២០។ (ហ៊ី ឆាយ)

កម្មករ-កម្មការិនីរោងចក្រមួយនៅសួនឧស្សាហកម្មកាណាឌីយ៉ា ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ នៅថ្ងៃនេះ បាននាំគ្នាតវ៉ាបិទផ្លូវចូលសួនមួយនេះរយៈពេល ៤ម៉ោង ដើម្បីទាមទារទៅម្ចាស់សួនឱ្យមានការអនុញ្ញាតដឹកអីវ៉ាន់ដែលលក់ឡាយឡុងចេញពីក្រុមហ៊ុន។

លោក ប៊ូ ថេត ដែលអះអាងថា ជាតំណាងកម្មករនៅរោងចក្រកាត់ដេរសម្លៀកបំពាក់ អ៊ិនធើណាស្យូណាល់ ហ្វេសស៊ិន រ៉ូយ៉ាល់ (INTERNATIONAL FASHION ROYAL CO., LTD) នៅសួនឧស្សាហកម្មកាណាឌីយ៉ា ស្ថិតក្នុងសង្កាត់ចោមចៅ បានរៀបរាប់ប្រាប់វីអូឌីកន្លែងតវ៉ាថា កាលពីពីរខែមុន ថៅកែរោងចក្រមួយនេះ បានប្រកាសបិទទ្វាររោងចក្រ ដោយពុំមានលុយបើកប្រាក់ឈ្នួល និងទូទាត់អត្ថប្រយោជន៍ផ្សេងៗជូនកម្មករឡើយ។

តំណាងកម្មកររូបនេះបន្តថា បន្ទាប់ពីគ្មានលទ្ធភាពដោះស្រាយសំណងជូនកម្មករ គឺថៅកែរោងចក្រ អ៊ិនធើណាស្យូណាល់ ហ្វេសស៊ិន រ៉ូយ៉ាល់ បានសម្រេចឱ្យក្រុមកម្មករលក់អីវ៉ាន់ និងសម្ភាររបស់ក្រុមហ៊ុន ដើម្បីយកលុយនោះ ដោះស្រាយសំណងជូនកម្មករ។

លោក ប៊ូ ថេត បន្ថែមថា ក្រោយតវ៉ា និងដេកយាមមុខរោងចក្រជាង ២ខែរួចមក គឺកាលពីសប្ដាហ៍មុននេះ ក្រុមកម្មករសម្រេចលក់អីវ៉ាន់ និងសម្ភារទាំងអស់របស់ក្រុមហ៊ុន ដោយទទួលបានកម្រៃជាង ១១ម៉ឺនដុល្លារ ដើម្បីបែងចែកទៅឱ្យកម្មករ ៩៣៩នាក់ ប៉ុន្តែ លោកថា បន្ទាប់ពីក្រុមកម្មករលក់បាន គឺម្ចាស់សួនកាណាឌីយ៉ាមិនអនុញ្ញាតឱ្យអ្នកទិញដឹកអីវ៉ាន់ និងសម្ភារទាំងនោះចេញពីរោងចក្រឡើយ។

> លោកបន្ថែមថា៖ «ដោយសារម្ចាស់សួនមិនអនុញ្ញាតឱ្យអ្នកទិញសម្ភារហ្នឹងដឹកអីវ៉ាន់ចេញ ដោយគាត់ឱ្យរង់ចាំថ្ងៃនេះ ថ្ងៃនោះ។ ដល់អីចឹង ធ្វើឱ្យកម្មករយើងពិបាក មិនអាចរង់ចាំបានទេ។ អីចឹងហើយបានជាពួកខ្ញុំមកទាំងអស់គ្នា ដើម្បីតវ៉ាសុំទៅអាជ្ញាធរពាក់ព័ន្ធជួយអន្តរាគមន៍ទៅខាងម្ចាស់សួនឱ្យអនុញ្ញាតឱ្យមានការដឹកអីវ៉ាន់ចេញទៅ គឺឈ្មួញអ្នកទិញហ្នឹងគេយកលុយមកដើម្បីបើកប្រាក់ខែជូនកម្មករហើយ»។

កម្មការិនីដែលអះអាងថា បម្រើការងារនៅរោងចក្រ អ៊ិនធើណាស្យូណាល់ ហ្វេសស៊ិន រ៉ូយ៉ាល់រយៈពេល ៥ឆ្នាំ អ្នកស្រី សាបាន ធារី ប្រាប់វីអូឌីកន្លែងតវ៉ាថា ការលក់អីវ៉ាន់ និងសម្ភាររបស់ក្រុមហ៊ុននោះ គឺអាចទូទាត់បានសម្រាប់តែប្រាក់ឈ្នួលចុងក្រោយរបស់កម្មករប៉ុណ្ណោះ ដោយមិនអាចទូទាត់អត្ថប្រយោជន៍ផ្សេងៗរបស់កម្មករបានឡើយ។

កម្មការិនីរូបនេះ អះអាងថា មូលហេតុដែលម្ចាស់សួនឧស្សាហកម្មកាណាឌីយ៉ាមិនអនុញ្ញាតឱ្យឈ្មួញដឹកអីវ៉ាន់ និងសម្ភាររបស់ក្រុមហ៊ុនចេញនោះ គឺដោយសារថៅកែរោងចក្រនៅជំពាក់ថ្លៃជួលអាគារប្រមាណ ១ម៉ឺន ៨៣ពាន់ដុល្លារទៀត។

អ្នកស្រី សាបាន ធារី លើកឡើងថា រយៈពេលកម្មករតវ៉ា និងដេកយាមមុខរោងចក្រ រង់ចាំដំណោះស្រាយនោះ គឺពួកគាត់ជួបការលំបាកច្រើនណាស់ ដោយពុំមានលុយចាយវាយប្រចាំថ្ងៃ គ្មានលុយបង់បន្ទប់ជួល ទឹកភ្លើង និងថ្លៃបង់សងធនាគារ ជាដើម។

> អ្នកស្រីបន្ថែមថា៖ «ពេលថៅកែអត់បើកលុយឱ្យអីចឹង គឺពួកខ្ញុំខ្វះខាតខ្លាំងណាស់។ ចងការលុយគេយកមកចាយបណ្ដោះអាសន្នសិន យកមកបង់ថ្លៃផ្ទះ ទឹកភ្លើង។ ហើយឥលូវ ម្ចាស់សួនកាណាឌីយ៉ាហ្នឹងគាត់អត់ឱ្យឈ្មួញដឹកអីវ៉ាន់ចេញ អីចឹងវារឹតតែធ្វើឱ្យពួកខ្ញុំពិបាកកាន់តែខ្លាំង។ ម្ចាស់សួនអត់ឱ្យដឹកអីវ៉ាន់ចេញហ្នឹង ដោយសារថៅកែជំពាក់លុយគាត់ ហើយម្ចាស់សួនហ្នឹងសុំកាត់លុយពីកម្មករខ្លះចំនួន ១ម៉ឺន ៨៣ពាន់ដុល្លារ បើគាត់កាត់ទៀត ពួកខ្ញុំអត់បានអីសោះ»។

វីអូឌីមិនទាន់អាចរកការសុំឆ្លើយតបពីតំណាងម្ចាស់សួនឧស្សាហកម្មកាណាឌីយ៉ាបានទេ ពាក់ព័ន្ធករណីនេះ។

មន្ត្រីខណ្ឌពោធិ៍សែនជ័យដែលប្រាប់ថា ឈ្មោះ លី ដែលចុះឃ្លាំមើលការតវ៉ានេះ មានប្រសាសន៍ថា លោកបានត្រឹមតែឃ្លាំមើល និងសម្របសម្រួលកុំឱ្យកើតមានអំពើហិង្សាផ្សេងៗប៉ុណ្ណោះ។ លោកថា តួនាទីក្នុងការដោះស្រាយបញ្ហានេះ គឺថ្នាក់លើ និងក្រសួងការងារ។

អ្នកនាំពាក្យក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ លោក ហេង សួរ ប្រាប់វីអូឌីតាមប្រព័ន្ធ Telegram ថា មន្ត្រីអធិការការងារ និងគណៈកម្មការដោះស្រាយកូដកម្មបាតុកម្មគ្រប់មុខសញ្ញា កំពុងចុះ និងសម្របសម្រួលដោះស្រាយបញ្ហានេះហើយ។

កាលពីថ្ងៃទី៨ ខែឧសភា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC) បានសុំទៅម្ចាស់អគារទាំងអស់ដែលកំពុងជួលកន្លែងឱ្យរោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនៅកម្ពុជា ចុះថ្លៃឈ្នួលយ៉ាងតិច ៣០ភាគរយ រយៈពេល ៣ខែ ទៅ ៦ខែ ដើម្បីជួយសម្រួលដល់ការចំណាយរបស់រោងចក្រ។

សមាគមមួយនេះលើកឡើងថា ឧស្សាហកម្មកាត់ដេរសម្លៀកបំពាក់ ផលិតស្បែកជើង និងផលិតផលផ្សេងទៀតធ្វើនៅកម្ពុជា កំពុងរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារជំងឺកូវីដ១៩ ដោយថា ការចំណាយរបស់រោងចក្រទៅលើថ្លៃជួលអគារ និងទីតាំង ក៏ជាបន្ទុកចំណាយដ៏ធ្ងន់ធ្ងរមួយដែរ ខណៈដែលសមាជិករបស់ខ្លួនកំពុងរងគ្រោះដោយសារការលុបចោលនៃការបញ្ជាទិញជាច្រើន និងគ្មានការបញ្ជាទិញថ្មីទៀតនោះ។

GMAC អះអាងថា ការចុះថ្លៃឈ្នួលរបស់ម្ចាស់អគារ និងម្ចាស់ទីតាំង នឹងអាចជួយសម្រាលបន្ទុកនៃការចំណាយរបស់រោងចក្រ និងចូលរួមចំណែកស្តារសេដ្ឋកិច្ចនៅកម្ពុជា ដើម្បីទ្រទ្រង់វិស័យមួយនេះ៕

---

**រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម**

សូមបញ្ជាក់ថា គ្មានផ្នែកណាមួយនៃអត្ថបទ រូបភាព សំឡេង និងវីដេអូទាំងនេះ អាចត្រូវបានផលិតឡើងវិញក្នុងការបោះពុម្ពផ្សាយ ផ្សព្វផ្សាយ ការសរសេរឡើងវិញ ឬ ការចែកចាយឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរឡើយ។
ស៊ីស៊ីអាយអឹម មិនទទួលខុសត្រូវចំពោះការលួចចម្លងនិងចុះផ្សាយបន្តណាមួយ ដែលខុស នាំឲ្យយល់ខុស បន្លំ ក្លែងបន្លំ តាមគ្រប់ទម្រង់និងគ្រប់មធ្យោបាយ។ ជនប្រព្រឹត្តិ និងអ្នកផ្សំគំនិត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់កម្ពុជា និងច្បាប់នានាដែលពាក់ព័ន្ធ។

## អត្ថបទទាក់ទង

### សូមផ្ដល់មតិយោបល់លើអត្ថបទនេះ

នាម និងគោត្តម *

សូមវាយបញ្ចូលឈ្មោះរបស់អ្នក

អ៊ីម៉ែល *

សូមវាយអាសយដ្ឋានអ៊ីម៉ែលរបស់អ្នក...

លេខទូរសព្ទ (មិនចាំបាច់)

បើសិនជាអ្នកចង់ឱ្យខាងក្រុមការងារ វីអូឌី ទាក់ទងទៅអ្នក សូមទម្លាក់លេខទូរសព្ទ ...

មតិយោបល់ *

សូមបញ្ចូលមតិយោបល់សម្រាប់អត្ថបទខាងលើនេះ...

Could not connect to the reCAPTCHA service. Please check your internet connection and reload to get a reCAPTCHA challenge.

ចុចបញ្ជូន

**ព័ត៌មានថ្មីៗ** | **បោះឆ្នោត**




លោក ហ៊ុន ម៉ាណែត បដិសេធមិនបានចុះហត្ថលេខាជំនួសនាយករដ្ឋមន្ត្រី រឿងផ្ដល់ជំនួយដល់ប្រទេសតួកគីនោះទេ

១២ កុម្ភៈ ២០២៣ ម៉ោង ១៨:១២

ធនាគារជាតិព្រមានវិធានការច្បាប់លើម្ចាស់គ្រឹះស្ថានគណទានទទួលយកអត្តសញ្ញាណប័ណ្ណឬសៀវភៅគ្រួសារពីកូនបំណុល

១២ កុម្ភៈ ២០២៣ ម៉ោង ១៣:១៤



ក្រសួងការងារថា ក្រុមហ៊ុន ខេមបូ ហែនសាំ យល់ព្រមទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារជូនកម្មករ

១១ កុម្ភៈ ២០២៣ ម៉ោង ១៦:១៣




អង់គ្លេសសង្ឃឹមថា ការបោះឆ្នោតជាតិខាងមុខនឹងប្រព្រឹត្តទៅដោយសេរី យុត្តិធម៌ និងគ្មានការគំរាមកំហែង



ព្រះមហាក្សត្រតែងតាំងសាស្ត្រាចារ្យផ្នែកប្រវត្តិសាស្ត្រលោក សំបូរ ម៉ាណ្ណារ៉ា ជាទីប្រឹក្សាលោក ហ៊ុន សែន



១១ កុម្ភៈ ២០២៣ ម៉ោង ១៥:៤៦



១១ កុម្ភៈ ២០២៣ ម៉ោង ១៤:៥៣






VOD គឺជាស្ថាប័នព័ត៌មានឯករាជ្យដែលផ្តល់ព័ត៌មាន ផលិតកម្មវិធីវិទ្យុ និងការផ្សព្វផ្សាយតាមរយៈគេហទំព័រអ៊ីនធើណេត។

info@vodhotnews.com

+៨៥៥ ២៣ ៧២៦ ៨៤៥ - លេខបន្ទាន់: +៨៥៥ ៩២ ៩២ ១៩ ០២ / +៨៥៥ ៦០ ៥០ ៥០ ៥០

ផ្ទះលេខ១៤A ផ្លូវ៣៩២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ




- ស្វែងរកព័ត៌មាន
- ព័ត៌មានជាសំឡេង
- VOD ENGLISH
- ទិន្នន័យចាស់ៗ
- អំពីយើង
- ក្រមសីលធម៌
- ទំនាក់ទំនង
- ឱកាសការងារ
- បណ្ណាសារូបភាព
- ទូរទស្សន៍

© ២០២២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម